# តំបន់សមុទ្រ (maritime zones)

តំបន់សមុទ្រ មិនរាប់បញ្ចូលដែនទឹកផ្ទៃក្នុងទេ (internal water) និងមានសមុទ្រដែនដី (territorial sea) , តំបន់តភ្ជាប់ (contiguous zone) , តំបន់សេដ្ឋកិច្ចផ្តាច់មុខ (Exclusive Economic zone), តំបន់លម្ហសមុទ្រអន្តរជាតិ (high sea) និងតំបន់បាតសមុទ្រអន្តរជាតិ (the Area)។

តំបន់ទាំងនេះ ត្រូវបានចែកជាតំបន់ស្ថិតនៅក្នុងអធិបតេយ្យ តំបន់ដែលរដ្ឋមានសិទ្ធិអធិបតេយ្យ និងតំបន់ស្ថិតនៅក្រៅដែនយុត្តាធិការជាតិ (high sea and the Area)។ តំបន់សេដ្ឋកិច្ចផ្តាច់មុខ មិនមានកំណត់ក្នុងអនុសញ្ញាពាក់ព័ន្ធសមុទ្រទាំងបួនឆ្នាំ១៩៥៨ ទេ ទើបមានក្នុងអនុសញ្ញាឆ្នាំ១៩៨២។ ដែនទឹកផ្ទៃក្នុង គឺជាដែនដី គិតពីខ្សែបន្ទាត់មូលដ្ឋានឆ្ពោះមកទិសខាងដីគោក។ បន្ថែមពីលើដែនទឹកផ្ទៃក្នុងធម្មតា ក៏មានដែនទឹកផ្ទៃក្នុងនៃរដ្ឋប្រជុំកោះ។ ក្នុងតំបន់ទាំងនេះ រដ្ឋមានសិទ្ធិឬករណីកិច្ចនិងអាចអនុវត្តយុត្តាធិការតាមប្រភេទផ្សេងស្របតាមអនុសញ្ញាឆ្នាំ១៩៨២។

ទទឹងនៃតំបន់ទាំងនេះ ត្រូវគិតវាស់ចេញពីខ្សែបន្ទាត់មូលដ្ឋាន ដែលខ្សែទាំងនេះ មានបប្រភេទ (ខ្សែបន្ទាត់មូលដ្ឋានធម្មតា, ខ្សែបន្ទាត់មូលដ្ឋានត្រង់ និងខ្សែបន្ទាត់មូលដ្ឋានប្រជុំកោះ)។




Figure 1: Offshore extent of the maritime zones recognized under international law




Maritime zones and rights under the 1982 United Nation Convention on the Law of the Sea (UNCLOS)

# រូបភាពពីគេហទំព័រជាសាធារណៈ